ONLINE
SMASHED
កម្ពុជា

# SMASHED ONLINE
## សេចក្តីណែនាំសម្រាប់គ្រូ

# វត្ថុបំណងរបស់យើង

វត្ថុបំណងរបស់យើងគឺបង្ហាញពីជំនឿរបស់យើងស្តីអំពីរបៀបដែលយើងដោះស្រាយទៅនឹងបរិបទនៃការប្រើប្រាស់គ្រឿងស្រវឹងទាំងមិនទាន់គ្រប់អាយុ និងពង្រឹងការ យល់ដឹងទាំងនេះទៅកាន់យុវជន។

- SMASHED គឺជាការអប់រំដែលផ្លាស់ប្តូរជីវិត
- ដំណោះស្រាយបញ្ហាការប្រើប្រាស់គ្រឿងស្រវឹងទាំងមិនទាន់គ្រប់អាយុជាមួយនឹងការគិតបែបវិជ្ជមាន
- អប់រំយុវជនអោយយល់ដឹងពីផលប៉ះពាល់ពីសម្ពាធពីមិត្តភក្តិនឹងត្រៀមខ្លួនទប់ទល់ជាមួយឥទ្ធិពលអវិជ្ជមាន
- ចំណេះដឹងគឺជាអំណាច
- នៅពេលអ្នកកំពុងប្រទះភាពមិនច្បាស់លាស់ក្នុងការសម្រេចចិត្តជុំវិញបញ្ហានោះ ត្រូវរកអ្នកពិភាក្សា
- ហើយនៅពេលដែលមិនផុតពីជម្រើសក្រោមការគាបសង្កត់ ត្រូវត្រៀមខ្លួនដើម្បីផ្តល់ដំណឹងទៅកាន់នរណាម្នាក់
- SMASHED ជាការអប់រំអំពីគ្រឿងស្រវឹង និងផ្តល់អំណាចនៃការសម្រេចចិត្តទៅកាន់យុវជន

# អំពីSMASHED

យុវជនមានសិទ្ធិទទួលបានការអប់រំអំពីគ្រឿងស្រវឹងដែលស្មោះត្រង់ សម្រេចចិត្តប្រកបដោយទំនុកចិត្ត និងបំផុសគំនិត។ យើងចង់ក្លាយជាសំឡេងនៃការផ្លាស់ប្តូរជាវិជ្ជមានសម្រាប់យុវជន ១០ លាននាក់នៅត្រឹមឆ្នាំ ២០៣០ ។ Smashed មាននៅក្នុងប្រទេសជាងម្ភៃប្រាំជុំវិញពិភពលោក។

# តើអ្វីជា SMASHED ONLINE ?

ស្រស់ស្រាយ, សប្បាយ និងងាយចូលរួម, Smashed Online រួមបញ្ចូលការសម្តែងល្ខោន និងវិធិសាស្ត្រសិក្សាបែបអន្តរកម្ម។ គម្រោងបរិយាយពីរឿងរ៉ាវដ៏មានឥទ្ធិពលនិងប្រាកដនិយមអំពីយុវជននិងគ្រឿងស្រវឹង។ អ្នកចូលរួមតែងសម្រាកមួយភ្លែតហើយសួរខ្លួនឯងថា" ចុះបើជាខ្ញុំវិញ ?" នៅក្នុងវគ្គសិក្សាតាមអ៊ីនធឺណេតដែលមានរយៈពេល ៦០ នាទី។

# គោលបំណងនៃការសិក្សា

សិស្សសង្កេត ស្វែងយល់ និងឆ្លុះបញ្ចាំងពីប្រធានបទការប្រើប្រាស់គ្រឿងស្រវឹងទាំងមិនទាន់គ្រប់អាយុក្រោមប្រធានបទសំខាន់ៗៈ

- មូលហេតុបង្កដោយសង្គម និងអារម្មណ៍
- ផលប៉ះពាល់លើជីវិតយុវវ័យ
- ឥទ្ធិពលសង្គម និងការសម្រេចចិត្ត
- ដំណោះស្រាយដើម្បីជួយខ្លួនឯង និងអ្នកដទៃ

# របៀបប្រើប្រាស់ SMASHED ONLINE

## វគ្គសិក្សាសម្រាប់ថ្នាក់រៀនជាក្រុម

- ចូលទៅកាន់ប៊ូតុង 'តើអ្នកជាគ្រូបង្រៀនឬ?' ជាមុនហើយចុះឈ្មោះចំនួនសិស្សក្នុងថ្នាក់
- ប្រើក្តារខៀន ឬម៉ាស៊ីនបញ្ចាំងដើម្បីអនុវត្តវគ្គសិក្សាជាក្រុម
- ប្រើសកម្មភាពអន្តរកម្មដើម្បីពិភាក្សាអំពីចំណុចសិក្សាជាមួយគ្នា
- ធ្វើការស្ទង់មតិសិស្សរហ័សរបស់យើងមុន និងក្រោយវគ្គសិក្សា ដើម្បីមើលវឌ្ឍនភាពរបស់សិស្ស និងទាញយកលទ្ធផល។ ដើម្បីរក្សាចំលើយរបស់ពួកគេជាអនាមិក សូមធ្វើតាមតំណ ដើម្បីប្រើប្រាស់សកម្មភាពសាមញ្ញៗរបស់យើង "ដាក់ក្បាលចុះ លើកដៃឡើង"។

## វគ្គសិក្សារៀងខ្លួន

- អ៊ីម៉ែលភ្ជាប់តំណវគ្គសិក្សាទៅសិស្ស
- សិស្សចុះឈ្មោះដោយរក្សាពត៌មានសម្ងាត់ផ្ទាល់ខ្លួន
- សិស្សបញ្ចប់កម្មវិធី Smashed Online តាមពេលវេលាផ្ទាល់ខ្លួន
- ពួកគេនឹងត្រូវបានសួរឱ្យឆ្លើយសំណួរងាយៗដូច្នេះយើងអាចតាមដានការវិវត្តរបស់សិស្ស
- ពួកគេអាចប្រើតំណភ្ជាប់ដែលមានប្រយោជន៍សម្រាប់ព័ត៌មានបន្ថែម ដំបូន្មាននិងការណែនាំនានា

# បញ្ចូលការរៀន

## កម្រងសំណួរ

បង្កើតកម្រងសំណួរសម្រាប់សិស្សអំពីគ្រឿងស្រវឹង និងគ្រោះថ្នាក់របស់វា។ រួមបញ្ចូលសំណួរអំពីអ្វីដែលបានកើតឡើងនៅក្នុងរឿង Smashed រួមទាំងផលវិបាកនៃការផឹកស្រាសម្រាប់តួអង្គនីមួយៗ។

## ការរចនាក្រាហ្វិច / សិល្បៈ

និស្សិតអាចការពារគ្រោះថ្នាក់នៃការផឹកស្រាមិនទាន់គ្រប់អាយុតាមរយៈការបង្កើតផ្ទាំងរូបភាព ឬការផ្សព្វផ្សាយតាមអ៊ីនធឺណិត។ លើកទឹកចិត្តពួកគេឱ្យលើកពីបញ្ហាប្រឈម និងបញ្ហាដែលតួអង្គជួបប្រទះនៅក្នុងរឿង។

## ល្ខោន

ប្រើសាច់រឿងជាការបំផុសគំនិតឱ្យសិស្សបង្កើតឈុតឆាកផ្ទាល់ខ្លួន ការផ្សព្វផ្សាយតាមអ៊ីនធឺណិត និងល្ខោននិយាយជុំវិញការប្រើប្រាស់គ្រឿងស្រវឹងមិនទាន់គ្រប់អាយុ។ ជួយពួកគេឱ្យស្វែងយល់ពីសម្ពាធរបស់មិត្តភក្តិ និងបង្កើតសាច់រឿងបញ្ចប់ជំនួសឱ្យ Smashed!

## ការសរសេរដែលមានគំនិតច្នៃប្រឌិត

សិស្សស្រមៃថាពួកគេជាមិត្តភក្តិ ឬសាច់ញាតិរបស់តួអង្គនៅចំណុចណាមួយនៅក្នុងភាពយន្ត។ តើពួកគេអាចផ្តល់យោបល់អ្វីខ្លះដល់តួអង្គ តាមរយៈអ៊ីមែលឬសំបុត្រ? ពួកគេអាចសរសេរអត្ថបទកាសែតអំពីឧប្បត្តិហេតុនៅចុងបញ្ចប់នៃ  រឿង។

## ការប្រកួតប្រជែង

សិស្សអាចបង្កើតឈុតឆាកឡើងវិញពីខ្សែភាពយន្ត Smashed ឬបង្កើតភាពយន្តឯកសារអំពីគ្រោះថ្នាក់នៃការផឹកមិនទាន់គ្រប់អាយុ។

## ប្រព័ន្ធផ្សព្វផ្សាយ

សិស្សអាចបង្កើតឈុតឆាកឡើងវិញពីខ្សែភាពយន្ត Smashed ឬបង្កើតភាពយន្តឯកសារអំពីគ្រោះថ្នាក់នៃការផឹកមិនទាន់គ្រប់អាយុ។



# វក្សាទំនាក់ទំនង

សូមអរគុណដែលបានអនុញ្ញាតអោយ Smashed ធ្វើកម្មវិធីនៅសាលារៀន និងជួយយុវជនស្វែងយល់ពីការសេពគ្រឿងស្រវឹងទាំងមិនទាន់គ្រប់អាយុ។ យើងសង្ឃឹមផងដែរថា Smashed បានផ្តល់ជូននូវបទពិសោធន៍នៃការរៀនសូត្រប្រកបដោយភាពច្នៃប្រឌិតដែលធ្វើអោយកម្មវិធីសិក្សាកាន់តែសំបូរបែប។ សូមចែករំលែកបទពិសោធន៍របស់អ្នកអំពី Smashed ជាមួយយើង និងអ្នកអប់រំដទៃទៀតផងដែរ!

- ឈ្មោះអង្គការ៖ សមាគមវប្បធម៌កម្ពុជា អាល្លឺម៉ង់
- អ៊ីមែល៖ mario.sopheap@gmail.com
- លេខទូរស័ព្ទទំនាក់ទំនង៖ ០២៣ ២១៨ ៩៨៧
- គេហទំព័រ៖ www.meta-house.com
- តំណភ្ជាប់គណនីប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គម៖
  www.facebook.com/MetaHousePhnomPenh/

Smashed គឺជាកម្មវិធីអប់រំសកលដែលបង្កើតឡើងដោយ Collingwood Learning នៅចក្រភពអង់គ្លេស។ សូមអរគុណចំពោះការឧបត្ថម្ភពី Diageo កម្ពុជា។ Smashed Online គឺពុំមានគិតថ្លៃនោះទេ។